00271485

C20/5/9

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| | | |
|---|---|---|
| សំណុំរឿងក្តីលេខ | : | 002/19-09-2007-អ.វ.ត.ក-ក.ស.ច.ស-(អ.ប.ជ១៦) |
| ដាក់ជូន | : | អង្គបុរេជំនុំជម្រះ |
| កាលបរិច្ឆេទរបស់ឯកសារ | : | ថ្ងៃទី១៩ ខែ មករា ឆ្នាំ២០០៩ |
| ភាគីដាក់ជូនសារណា | : | មេធាវីការពារក្តីរបស់អ្នកស្រី **អៀង ធីរិទ្ធ** |
| ភាសាដើម | : | ភាសាអង់គ្លេស និងភាសាខ្មែរ (បកប្រែ) |
| ប្រភេទនៃឯកសារ | : | សាធារណៈ |

---

## ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញា ដើម្បីកំណត់អំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបន្តឋិរៈ ទេលាឃុំខ្លួនបណ្តោះអាសន្នដោយផ្អែកលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខអក្សរតែប៉ុណ្ណោះ

---

<u>ដាក់ជូនដោយ</u>:
**មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ:**
ផាត់ ពៅស៊ាង
Diana ELLIS, QC

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
19 / 01 / 2009
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Any

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification):
20 / 01 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Any

<u>ជូនចំពោះ</u>:
**អង្គបុរេជំនុំជម្រះ:**
ប្រាក់ គឹមសាន, ប្រធាន
ហ្វ៊ួត វុទ្ធី
Rowan DOWNING
ន័យ ធុល
Katinka LAHUIS
ប៉ែន ពេជ្រសាលី
**សហព្រះរាជអាជ្ញា:**
ជា លាង
Robert PETIT
**មេធាវីរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី:**
ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke STUDZINSKY
យុង ផានិត
គឹម ម៉េងឃី
Martin JACQUIN

## I. សេចក្តីផ្តើម

១. នៅថ្ងៃទី៩ ខែ ធ្នូ ឆ្នាំ២០០៨, មេធាវីការពារក្តីបានដាក់នូវ "សារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងទៅនឹងដីកាសម្រេចបន្តថិរៈវេលាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៨" (បណ្តឹងឧទ្ធរណ៍)[1] ។

២. នៅក្នុងចម្លើយតបរបស់ សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវី ការពារក្តីប្រឆាំងនឹង "ដីកាសម្រេចបន្តថិរៈវេលាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១០ ខែវិច្ឆិកា ២០០៨"[2]។ ការិយាល័យសហព្រះរាជអាជ្ញា(ក.ស.ព)ស្នើសុំអង្គបុរេជំនុំជម្រះ (អ.ប.ជ) កំណត់អំពីបណ្តឹងឧទ្ធរណ៍នេះដោយផ្អែកលើតែសេចក្តីសន្និដ្ឋានជាលាយលក្ខអក្សរប៉ុណ្ណោះ (សំណើរបស់ ក.ស.ព)[3] ។

៣. នៅថ្ងៃទី ១៤ ខែ មករា ២០០៩, អ.ប.ជ បានចេញនូវ "សេចក្តីបង្គាប់ដល់ភាគីចំពោះសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំដើម្បីកំណត់អំពីបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើតែសេចក្តីសន្និដ្ឋានជាលាយលក្ខអក្សរប៉ុណ្ណោះ" (សេចក្តីបង្គាប់)[4] ដែលបង្គាប់ឲ្យភាគីឆ្លើយតបចំពោះសំណើនេះ នៅថ្ងៃ ច័ន្ទ ទី ១៩ ខែ មករា ២០០៩ ។ ហេតុដូច្នេះ មេធាវីការពារក្តីសូមដាក់ជូននូវចម្លើយតបរបស់ខ្លួនទៅនឹងសេចក្តីបង្គាប់នេះ ។

## II. អង្គច្បាប់

៤. វិធានផ្ទៃក្នុង ៧៧ (៣)(ខ) បានចែងថា:

បន្ទាប់ពីបានពិចារណាលើការយល់ឃើញរបស់ភាគី អង្គបុរេជំនុំជម្រះ អាចសម្រេចលើបណ្តឹងឧទ្ធរណ៍ ឬពាក្យសុំដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខអក្សររបស់ភាគីតែប៉ុណ្ណោះ។

៥. តាមមូលដ្ឋាននេះ ក.ស.ច បានស្នើសុំ អ.ប.ជ ដើម្បីកំណត់អំពីបណ្តឹងឧទ្ធរណ៍នេះដោយផ្អែកទៅលើតែសេចក្តីសន្និដ្ឋានជាលាយលក្ខអក្សរជំនួសសវនាការដោយផ្ទាល់មាត់វិញ

---

[1] មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ ប្តឹងឧទ្ធរណ៍ប្រឆាំងនឹង "ដីកាសម្រេចបន្តថិរៈវេលាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១០ ខែវិច្ឆិកា ២០០៨, នៅថ្ងៃទី ៩ ខែ ធ្នូ ២០០៨, ឯកសារលេខ: C20/5/1។

[2] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងដីកាសម្រេចបន្តថិរៈវេលាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១០ ខែវិច្ឆិកា ២០០៨, នៅថ្ងៃទី ៩ ខែ មករា ២០០៩,ឯកសារលេខ:C20/5/7។

[3] សំណើរបស់ ក.ស.ព, កថាខណ្ឌទី ៤ ។

[4] សេចក្តីបង្គាប់ដល់ភាគីចំពោះសំណើរបស់សហព្រះរាជអាជ្ញាដើម្បីកំណត់លើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខអក្សរតែប៉ុណ្ណោះ, ថ្ងៃទី ១៤ ខែមករា ២០០៩,ឯកសារលេខ: C20/5/8 ។

ហើយនោះវាអាស្រ័យលើ អ.ប.ជ ដែលមានឆន្ទានុសិទ្ធិនៅក្នុងការសម្រេចចំពោះសំណើសុំបែបនេះ។

III. អំណះអំណាង

៦. សំណើរបស់ ក.ស.ព ទំនងជាសន្និដ្ឋានថា មេធាវីការពារក្តីនឹងមិនជំទាស់ទៅនឹងការធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខអក្សរទេមើលទៅ ដោយអះអាងថា "អ្នកប្តឹងឧទ្ធរណ៍មិនបានសុំឲ្យមានសវនាការផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍នេះ"[5]។ ក៏ប៉ុន្តែ ការសន្មត់នៃវិធានផ្ទៃក្នុង ៧៧(៣)(ខ)គឺជាសវនាការផ្ទាល់មាត់។ ដោយមិនធ្វើការបកស្រាយលើបញ្ហានេះទេ ប៉ុន្តែមេធាវីការពារក្តីសូមគាំទ្រឲ្យមានសវនាការផ្ទាល់មាត់។ អាស្រ័យហេតុនេះ មេធាវីការពារក្តីសូមជំទាស់ទៅនឹងសំណើរបស់ ក.ស.ព ហើយស្នើសុំ អ.ប.ជ មេត្តាសម្រេចអំពីបញ្ហានេះដោយផ្អែកលើមូលដ្ឋាននៃសវនាការផ្ទាល់មាត់វិញ ។

៧. សំណើរបស់ ក.ស.ព បានទទួលស្គាល់ថា "សវនាការអំពីការកំណត់នៃការឃុំខ្លួនគប្បីត្រូវតែធ្វើឡើងដោយផ្ទាល់មាត់" ។ ក៏ប៉ុន្តែ ខ្លួនបានអះអាងថាបណ្តឹងឧទ្ធរណ៍នេះគប្បីត្រូវបានកំណត់ដោយផ្អែកលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខអក្សរតែប៉ុណ្ណោះ ដោយសារតែបណ្តឹងនេះពាក់ព័ន្ធតែចំពោះការបន្តថិរវេលានៃការឃុំខ្លួន, ហេតុដូចនេះហើយ "វាមិនមានអំណះអំណាងលើអង្គហេតុ ឬអង្គច្បាប់ថ្មីដែលត្រូវលើកឡើងនៅក្នុងសវនាការផ្ទាល់មាត់នោះទេ"[6]។

៨. មេធាវីការពារក្តីសូមតវ៉ាចំពោះការចោទប្រកាន់បែបនេះ ។ សំណើរបស់ ក.ស.ព ត្រូវការ ២៧ទំព័រដើម្បីឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ហើយវាជាក់ស្តែងដែលបានពាក់ព័ន្ធទៅនឹងអំណះអំណាងលើអង្គហេតុ និងអង្គច្បាប់ថ្មីៗទៀត ។

៩. ការឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទបានត្រូវគេបន្តសំរាប់មួយឆ្នាំទៀត ហើយមេធាវីការពារក្តីប្រឆាំងនឹងមូលដ្ឋាននៃការបន្តឃុំខ្លួននេះ ដែលការិយាល័យសហចៅក្រមស៊ើបអង្កេតបានចេញ "ដីកាសម្រេចបន្តរថិរវេលាឃុំខ្លួនបណ្តោះអាសន្ន"[7]

[5] សំណើរបស់ ក.ស.ព, កថាខណ្ឌ ៤ ។

[6] សំណើរបស់ ក.ស.ព, កថាខណ្ឌ ៤ ។

[7] ដីកាសម្រេចបន្តថិរៈវេលាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ២០០៨, ឯកសារលេខ: C20/4

00271488



គឺមិនមានហេតុផលគ្រាប់គ្រាន់ និងមានកំហុស ហេតុដូច្នេះហើយវាគប្បីត្រូវបានបដិសេធចោល។

១០. ហេតុដូច្នេះ ដីកាសម្រេចបន្តឋិរៈវេលាឃុំខ្លួនបណ្ដោះអាសន្នពិតជាបញ្ហាដ៏សំខាន់ចំពោះជនត្រូវចោទ ហើយគួរតែត្រូវដោះស្រាយឱ្យបានសមស្រប ។ ភាគីទាំងអស់គួរតែត្រូវបានអនុញ្ញាតឱ្យបង្ហាញនូវអំណះអំណាងរបស់ពួកគេដោយផ្ទាល់មាត់ ដើម្បីអោយមានលទ្ធភាពពេញលេញក្នុងការពន្យល់អំណះអំណាងលើបណ្ដឹងឧទ្ធរណ៍នេះ។ ជាពិសេសត្រូវផ្ដល់នូវការបកស្រាយខុសៗគ្នាជាច្រើនអំពីអង្គហេតុ និងអង្គច្បាប់ដែលមាននៅក្នុងឯកសាររបស់មេធាវីការពារក្ដី និង សហព្រះរាជអាជ្ញា ហើយដែលបញ្ហាទាំងអស់នេះគប្បីត្រូវធ្វើការជជែក និងបំភ្លឺបន្ថែមទៀតនៅតុលាការ ។

## IV. សំណូមពរ

១១. សំរាប់ហេតុផលទាំងអស់នេះ មេធាវីការពារក្ដីសូមស្នើអង្គបុរេជំនុំជម្រះដើម្បីសំរេចលើបណ្ដឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋាននៃសេចក្ដីសន្និដ្ឋានផ្ទាល់មាត់ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៩ ខែ មករា ឆ្នាំ២០០៩

AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

សហមេធាវី លោកស្រី ដាយ៉ាណា អេលីស

Ms. Diana ELLIS, QC